**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......១៤៧/២៥.........ក.ប/ស.ណ.ន.ព.ក

## សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងវិធានការសុវត្ថិភាព និងសុខភាពការងារក្នុងករណីមានគ្រោះជំនន់ទឹកភ្លៀង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិតទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីបង្ការហានិភ័យដែលអាចកើតមានឡើងជាយថាហេតុដោយសារគ្រោះជំនន់ទឹកភ្លៀងនៅក្នុងភូមិសាស្ត្រ ដែលមានសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកន្លែងស្នាក់នៅរបស់កម្មករនិយោជិត ក្រសួងសូមធ្វើការណែនាំដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិតទាំងអស់ ត្រូវពង្រឹងការអនុវត្តនូវវិធានការសុវត្ថិភាព និងសុខភាពការងារដូចខាងក្រោមៈ

### ក-ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ

១- តាមដានស្ថានភាពទឹកជំនន់ជាប្រចាំនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។

២- បង្កើតក្រុមការងារទទួលបន្ទុក និងរៀបចំបណ្តាញទំនាក់ទំនងឱ្យបានច្បាស់លាស់ ព្រមទាំងត្រៀមផែនការជួយសង្គ្រោះ មធ្យោបាយការពារ និងជម្លៀសកម្មករនិយោជិត ក្នុងករណីមានទឹកជំនន់។

៣- ត្រួតពិនិត្យបណ្តាញអគ្គិសនីឱ្យបានត្រឹមត្រូវសមស្របតាមលក្ខណៈបច្ចេកទេស និងសុវត្ថិភាព សម្រាប់បង្ការ និងបញ្ចៀសបញ្ហាជាយថាហេតុណាមួយ។

៤- រៀបចំវិធានការសង្គ្រោះបឋម និងវិធីសាស្ត្រជួយសង្គ្រោះជាអាទិ៍ ក្នុងករណីលង់ទឹក ឆក់ចរន្តអគ្គិសនី សត្វទិច ចឹក ឬខាំ។

៥- ទុកដាក់វត្ថុធាតុដើម សម្ភារៈសំខាន់ៗ និងសារធាតុគីមីឱ្យបានត្រឹមត្រូវផុតពីទឹក និងមានសុវត្ថិភាព ជាពិសេសវត្ថុធាតុដើម និងសារធាតុគីមីដែលមានប្រតិកម្មជាមួយទឹក។

៦- រៀបចំដាក់ស្លាកសញ្ញាការហាមឃាត់នៅកន្លែងដែលមានគ្រោះថ្នាក់ ទឹកជន់លិច ឬហូរខ្លាំង។

៧- ត្រៀមស្បៀងអាហារ ទឹកស្អាតសម្រាប់បរិភោគ និងថ្នាំសង្កូវឱ្យបានគ្រប់គ្រាន់អំឡុងពេលរង់ចាំក្រុមជួយសង្គ្រោះទៅដល់ ក្នុងករណីកម្មករនិយោជិតជាប់គាំងក្នុងសហគ្រាស ក្រុមហ៊ុន រោងចក្រ នៅពេលមានទឹកជំនន់។

៨- អប់រំ ណែនាំ និងផ្សព្វផ្សាយដល់កម្មករនិយោជិតអំពីវិធានការសុវត្ថិភាព និងសុខភាពការងារ ដើម្បីការពារសុវត្ថិភាពកម្មករនិយោជិតនៅពេលមានទឹកជំនន់កើតឡើង។

៩- ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធសុវត្ថិភាពផ្សេងៗ សម្អាតបរិវេណសហគ្រាស ក្រុមហ៊ុន រោងចក្រ និងធ្វើអនាម័យបង្គន់ឡើងវិញ មុននឹងចាប់ផ្តើមដំណើរការប្រវាក់ផលិតកម្ម ឬសកម្មភាពអាជីវកម្មឡើងវិញ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

១០- អនុវត្តឱ្យបានហ្មត់ចត់តាមវិធានការរបស់អាជ្ញាធរមូលដ្ឋាន និងវិធានការនានារបស់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសហការឱ្យបានពេញលេញជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីមានការណែនាំជាក់ស្តែង។

**ខ-កម្មករនិយោជិត**

១- បង្កើនការប្រុងប្រយ័ត្នគ្រោះថ្នាក់ផ្ទាល់ខ្លួនជាអាទិ៍ លង់ទឹក ឆក់ចរន្តអគ្គិសនី សត្វទិច ចឹក ឬខាំ។

២- ផ្តល់ព័ត៌មានអំពីស្ថានភាពសុវត្ថិភាព និងសុខភាពការងាររបស់ខ្លួនទៅកាន់និយោជកជាប្រចាំក្នុងអំឡុងពេលឈប់សម្រាកដោយសារគ្រោះទឹកជំនន់។

៣- អនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមការណែនាំរបស់និយោជក និងអាជ្ញាធរពាក់ព័ន្ធ។

៤- អនុវត្តឱ្យបានហ្មត់ចត់តាមវិធានការរបស់អាជ្ញាធរមូលដ្ឋាន និងវិធានការនានារបស់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសហការឱ្យបានពេញលេញជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីមានការណែនាំជាក់ស្តែង។

ក្នុងករណីចាំបាច់ ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិត អាចទាក់ទងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈប្រព័ន្ធ Hotline លេខ ១២៨៦ ឬ ស្កេន QR Code ខាងក្រោម ដើម្បីអធិការការងារចុះធ្វើការវាយតម្លៃកម្រិតហានិភ័យ ដែលអាចកើតមានឡើងចំពោះសុវត្ថិភាពកម្មករនិយោជិតក្នុងអំឡុងពេលមានទឹកជំនន់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ចន្ទ ៦រោច ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

"សម្រាប់និយោជក" "សម្រាប់កម្មករនិយោជិត" "បណ្តឹងអនាមិក"

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ